

# សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមរម្យ (ឬត្រូវដោះលែង) និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល

## និយមន័យ



សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមរម្យ (ឬត្រូវដោះលែង) និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលតម្រូវឱ្យមានដំណើរការនីតិវិធីព្រហ្មទណ្ឌដែលត្រូវធ្វើឡើងនៅក្នុងរយៈពេលសមរម្យ។

សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមរម្យ (ឬត្រូវដោះលែង) អនុវត្តតែចំពោះបុគ្គលដែលត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងត្រូវបានឃុំខ្លួនបណ្ដោះអាសន្នប៉ុណ្ណោះ ខណៈដែលសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលមានវិសាលភាពទូលំទូលាយជាងនេះ។ សិទ្ធិនេះអនុវត្តចំពោះបុគ្គលគ្រប់រូបដែលត្រូវចោទពីបទព្រហ្មទណ្ឌមិនថាឃុំខ្លួន ឬមិនឃុំខ្លួននោះទេ។





សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមរម្យ (ឬត្រូវដោះលែង) អនុវត្តជាក់លាក់ចំពោះរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន ឧ. ការឃុំខ្លួននៅចន្លោះពេលចាប់ខ្លួន និងការចេញសេចក្ដីសម្រេចរបស់សាលាដំបូង។ សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលមានវិសាលភាពក្នុងការអនុវត្តទូលាយ។ ការធានានេះអនុវត្តចាប់ពីពេលដែលមានការចោទប្រកាន់ រហូតដល់ការសម្រេចសេចក្ដីចុងក្រោយបិទបណ្ដឹងប្ដឹងតវ៉ា។

ពុំមានថេរវេលាកំណត់ជាក់លាក់ ដែលបានកំណត់ថា តើពេលវេលាប៉ុណ្ណាដែលជាពេលវេលាសមរម្យ ឬគ្មានការពន្យារពេលនោះទេ។ ភាពសមរម្យនៃពេលវេលាក្នុងការនាំយកជនត្រូវចោទ ដែលត្រូវបានឃុំខ្លួនមកជំនុំជម្រះ ឬការពន្យារពេលក្នុងការដំណើរការនីតិវិធីព្រហ្មទណ្ឌត្រូវឆ្លងកាត់ការវាយតម្លៃទៅតាមករណីនីមួយៗ ដោយត្រូវធ្វើការពិចារណាទៅលើកាលៈទេសៈនៃសំណុំរឿងទាំងនោះ ភាពស្មុគស្មាញនៃសំណុំរឿង ការប្រព្រឹត្តរបស់ជនជាប់ចោទក្នុងអំឡុងពេលដំណើរការនីតិវិធី និងរបៀប ដែលមន្ត្រីតុលាការដោះស្រាយសំណុំរឿងនោះ។





នេះគឺជាតួនាទីរបស់អាជ្ញាធររដ្ឋក្នុងការរៀបចំ និងធ្វើយ៉ាងណាផ្ដល់ធនធានឱ្យបានគ្រប់គ្រាន់សម្រាប់ប្រព័ន្ធច្បាប់ ដើម្បីធានាឱ្យមានយុត្តិធម៌យ៉ាងឆាប់រហ័ស។ ប្រសិនបើអាជ្ញាធរមិនបាននាំជនជាប់ចោទដែលកំពុងស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្នមកកាន់សវនាការនៅក្នុងពេលវេលាសមរម្យទេនោះ ពួកគេត្រូវតែដោះលែងជនជាប់ចោទនោះ។

# ក្របខ័ណ្ឌច្បាប់

## ច្បាប់អន្តរជាតិ



សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមរម្យ (ឬត្រូវដោះលែង) និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលត្រូវបានធានាដោយមាត្រា ៩ (៣) "បុគ្គលណាដែលបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌនឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរណាមួយផ្សេងទៀតដែលអនុញ្ញាតដោយច្បាប់ឱ្យបំពេញមុខងារជាតុលាការ និងត្រូវបានជំនុំជម្រះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង។" និងមាត្រា ១៤ (៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ "ក្នុងការសម្រេចសេចក្តី ចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយ ប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួល [...] បានការជំនុំជម្រះដោយឥតពន្យារពេលយូរហួសហេតុ [...]។"

## ច្បាប់ជាតិ




សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមរម្យ (ឬត្រូវដោះលែង) និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលត្រូវបានធានាដោយមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា "[...] សេចក្តីសម្រេចរក្សាទុកជនត្រូវចោទក្នុងឃុំជាបណ្តោះអាសន្នលែងមានអនុភាពក្នុងរយៈពេល៤ខែ។ ប្រសិនបើជនត្រូវចោទមិនបានចូលទៅបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេល ៤ ខែនោះទេ ជនត្រូវចោទនេះត្រូវដោះលែងឱ្យនៅក្រៅឃុំបណ្តោះអាសន្នដោយឯកឯង...[...]។"

# សារសំខាន់



សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមរម្យ (ឬត្រូវដោះលែង) និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល គឺជាសិទ្ធិមូលដ្ឋានមួយ ដែលអាចការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ សិទ្ធិទាំងពីរនេះមានសារសំខាន់ណាស់ក្នុងការរក្សាសិទ្ធិមានសេរីភាព និងការសន្មតទុកជាមុនថាគ្មានទោស ដោយសារតែសិទ្ធិទាំងនេះជៀសវាងការឃុំខ្លួនបណ្តោះអាសន្នរយៈពេលយូរហួសហេតុ និងការឃុំខ្លួនបុគ្គលរយៈពេលយូរជាងភាពចាំបាច់នៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ។



សិទ្ធិទាំងពីរនេះ ជួយឱ្យដំណើរការផ្តល់យុត្តិធម៌មានភាពឆាប់រហ័ស ដែលជាគោលគំនិតដ៏សំខាន់នៃការជំនុំជម្រះដោយយុត្តិធម៌ ដោយសារតែដំណើរការយុត្តិធម៌ត្រូវធ្វើឱ្យឆាប់រហ័ស ជៀសវាងការឃុំខ្លួនបុគ្គលក្នុងរយៈពេលយូរ ក្នុងស្ថានភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងការចោទប្រកាន់មកលើពួកគេ។ សិទ្ធិទាំងពីរនេះត្រូវបានធានាផងដែរថា ផលប្រយោជន៍នៃយុត្តិធម៌ត្រូវបានផ្តល់ជូន។ យ៉ាងណាក៏ដោយ ត្រូវពិនិត្យមើលតុល្យភាពរវាងភាពចាំបាច់នៃដំណើរការយុត្តិធម៌ឆាប់រហ័ស និងការលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ (ឧ. សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី)។

# ដែនកំណត់

សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមរម្យ (ឬត្រូវដោះលែង) និងសិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល មិនហាមឃាត់ចំពោះការអូសបន្លាយពេលនៃដំណើរការនីតិវិធីព្រហ្មទណ្ឌណាមួយនោះទេ។ ការពន្យារពេលមួយចំនួនអាចមានហេតុផលដោយសារតែភាពស្មុគស្មាញនៃសំណុំរឿង ឬការប្រព្រឹត្តរបស់ជនជាប់ចោទ។ ប៉ុន្តែ ការពន្យារពេល ដែលបង្កឡើងដោយការស្ទះដំណើរការនីតិវិធីតុលាការខ្វះខាតធនធានមនុស្ស (ឧ. កង្វះចៅក្រម) ឬការធ្វេសប្រហែសរបស់អាជ្ញាធរ មិនអាចជាមូលហេតុនៃការពន្យារពេលដំណើរការនីតិវិធីព្រហ្មទណ្ឌនោះទេ។

ខែកញ្ញា ឆ្នាំ២០២២

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

Sweden
Sverige

People Change the World
Diakonia

cc BY NC SA